ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៦ - សរណន

# សារាចរណែនាំ
## ស្តីពី
## ការធ្វើអាជីវកម្មល្បែងកំសាន្តអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ (ស្លតម៉ាស៊ីន)

ស្ថានភាពនយោបាយ និងសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានលក្ខណៈល្អប្រសើរ ធ្វើឱ្យការអភិវឌ្ឍលើគ្រប់វិស័យបានបោះជំហានទៅមុខគួរឱ្យកត់សំគាល់ ហើយការការពារសន្តិសុខ និងសុវត្ថិភាពជូនប្រជាពលរដ្ឋ ក៏ត្រូវបានពង្រឹងជាបន្តបន្ទាប់ ។ កត្តាទាំងនេះបានធ្វើឱ្យចំនួនភ្ញៀវទេសចរបរទេសចូលមកទស្សនានៅព្រះរាជា-ណាចក្រកម្ពុជាយើងកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ។

កន្លងមក ដើម្បីបំរើសេចក្តីត្រូវការ និងការកំសាន្តសប្បាយ របស់ភ្ញៀវទេសចរបរទេស និងតាមសំណើរបស់ក្រុមហ៊ុនមួយចំនួន រាជរដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតជាគោលការណ៍ឱ្យបើកមជ្ឈមណ្ឌលកំសាន្ត ឬក្លឹបកំសាន្ត បំពាក់ដោយម៉ាស៊ីនអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ (មិនមែនកាស៊ីណូ) នៅតាមសណ្ឋាគារនៅក្នុងរាជធានី និងខេត្ត-ក្រុងមួយចំនួន ។ ប៉ុន្តែ រាជរដ្ឋាភិបាលពិនិត្យឃើញថា ក្រុមហ៊ុនដែលបានទទួលអាជ្ញាប័ណ្ណឱ្យបើកធ្វើអាជីវកម្មល្បែងកំសាន្តអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ (ស្លតម៉ាស៊ីន) មួយចំនួនមិនបានគោរពទៅតាមសៀវភៅបន្ទុក ។ ប្រការទាំងនេះបានធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈ នៅក្នុងរាជធានីភ្នំពេញ និងខេត្ត-ក្រុងមួយចំនួនទៀត ។

ដូច្នេះ ដើម្បីធ្វើការគ្រប់គ្រងអាជីវកម្មល្បែងកំសាន្តអេឡិចត្រូនិចនិងមេកានិចគ្រប់ប្រភេទ (ស្លតម៉ាស៊ីន) ប្រកបដោយប្រសិទ្ធភាព និងស្របតាមបទដ្ឋានបច្ចេកទេស រាជរដ្ឋាភិបាលកម្ពុជាដាក់វិធានការឱ្យអនុវត្តដូចខាងក្រោម :

១- បន្ទាប់ពីមានការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាល ត្រូវមានអាជ្ញាប័ណ្ណធ្វើអាជីវកម្មពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

២- ត្រូវមានទីតាំងធ្វើអាជីវកម្មតែនៅក្នុងសណ្ឋាគារ ដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវពីក្រសួងទេសចរណ៍ និងមិនអនុញ្ញាតឱ្យមានសាខាឡើយ ។ ចំពោះក្រុមហ៊ុនដែលមានអាជ្ញាប័ណ្ណធ្វើអាជីវកម្មហើយ មានទីតាំងមិនស្ថិតនៅក្នុងសណ្ឋាគារ ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបញ្ឈប់សកម្មភាពអាជីវកម្មជាបណ្តោះអាសន្ន និងតំរូវឱ្យក្រុមហ៊ុនរើទីតាំងរបស់ខ្លួនចូលទៅក្នុងសណ្ឋាគារ

ក្នុងរយៈពេល ៦ខែ យ៉ាងយូរ គិតចាប់ពីថ្ងៃចេញសារាចរណែនាំនេះ ។ ក្នុងករណីមិនបំពេញតាមលក្ខខណ្ឌនេះ ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបញ្ឈប់សកម្មភាពអាជីវកម្ម និងដកហូតអាជ្ញាប័ណ្ណជាស្ថាពរ ។

៣- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវដកហូតអាជ្ញាប័ណ្ណចំពោះក្រុមហ៊ុនទាំងឡាយណាដែលមិនបានអនុវត្តទៅតាមប្រកាសលេខ ២៨៧សហវ.ប្រក និងល័ក្ខខ័ណ្ឌផ្តល់អាជ្ញាប័ណ្ណ ដូចមានចែងនៅក្នុងសៀវភៅបន្ទុក និងចំណុច ២ ខាងលើ ។

៤- ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចាត់វិធានការបង្ក្រាបជាបន្ទាន់ ចំពោះមជ្ឈមណ្ឌលកំសាន្តអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ (ស្លុតម៉ាស៊ីន) ដែលគ្មានការអនុញ្ញាតពីរាជរដ្ឋាភិបាល និងគ្មានអាជ្ញាប័ណ្ណចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៥- មិនអនុញ្ញាតឱ្យប្រជាពលរដ្ឋខ្មែរចូលលេងជាដាច់ខាត ។ បើមានការខុសឆ្គងប្រការណាមួយ ដូចជាមានការអនុញ្ញាតឱ្យប្រជាពលរដ្ឋខ្មែរចូលលេង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវដកអាជ្ញាប័ណ្ណបញ្ឈប់អាជីវកម្មក្នុងរយៈពេល ២៤ម៉ោង ក្រោយគំហើញ ។

៦- អាជ្ញាធរដែនដីខេត្ត-ក្រុង ព្រមទាំងស្ថាប័នផ្សេងទៀត ពុំមានសិទ្ធិចេញលិខិតអនុញ្ញាតឱ្យបើកមជ្ឈ-មណ្ឌលកំសាន្តអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ (ស្លុតម៉ាស៊ីន) ឡើយ ។

៧- ក្នុងករណីចាំបាច់ ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំបែបបទប្តឹងទៅស្ថាប័នតុលាការ ចំពោះម្ចាស់មជ្ឈមណ្ឌលកំសាន្តអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ (ស្លុតម៉ាស៊ីន) ដែលអនុវត្តខុសពីសារាចរណែនាំនេះ ។

ទទួលបានសារាចរណែនាំនេះ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងទេសចរណ៍ អាជ្ញាធរដែនដីខេត្ត-ក្រុង ព្រមទាំងស្ថាប័នពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់សហការអនុវត្តសារាចរណែនាំនេះឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>ចម្លងជូន:</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងទេសចរណ៍
  "ដើម្បីអនុវត្ត"
- គ្រប់សាលាខេត្ត-ក្រុង
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ